# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC) Project

ខែ កញ្ញា ឆ្នាំ ២០១១

លេខ ៧

## ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

### លទ្ធផលសម្រេចបាន

- សិស្សានុសិស្សចំនួន ៣៨,៥៤២ នាក់ទទួលបានការបំប៉នពីរបៀបប្រើប្រាស់អនាម័យទឹកស្អាត
- សៀវភៅកម្មវិធីសិក្សាបំណិនជីវិតសម្រាប់គ្រូចំនួន២៨មុខវិជ្ជាក្នុងចំណោម៣០ចាប់ផ្តើមប្រើសាកល្បងនៅឆ្នាំក្រោយ និងបញ្ចប់សម្រាប់បោះពុម្ពក្នុងខែ កក្កដា និងសីហា
- ក្លឹបមុខវិជ្ជាក្នុងពេលបច្ចុប្បន្នមានចំនួន ៦២ ក្លឹបក្នុងចំណោម ២៤ សាលារៀន

### ដៃគូគម្រោង IBEC

- គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

  គម្រោងត្រូវប្រតិបត្តិដោយអង្គការអប់រំពិភពលោក ដោយមានកិច្ចសហការជាមួយអង្គការខេប និងសហប្រតិបត្តិការជាមួយក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ។

- ដៃគូក្នុងស្រុកផ្សេងទៀតមានអង្គការ ៖ WCRD, BSDA, NEP និង EDA
- ដៃគូអន្តរជាតិមានអង្គការ ៖ Equal Access និង AIR

## IBEC ដឹកនាំសិក្ខាសាលាថ្នាក់ជាតិអំពីការអនុវត្តល្អ

### សិក្ខាសាលាថ្នាក់ជាតិ និងកម្មវិធីទស្សនៈកិច្ចសាលារៀនដែលរៀបចំដោយ NEP

សិក្ខាសាលាធំថ្នាក់ជាតិលើកទីពីររបស់គម្រោង IBEC ត្រូវបានរៀបចំឡើងដោយអង្គការភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល (NEP) កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ។ សិក្ខាសាលាប្រចាំឆ្នាំនេះធ្វើឡើងដើម្បីចែករំលែកនូវសកម្មភាពដែលអនុវត្តបានល្អ និងបទពិសោធន៍ល្អៗមួយចំនួនរបស់គម្រោង IBEC ជាមួយអង្គការក្រៅរដ្ឋាភិបាលដ៏ទៃទៀតដែលធ្វើការក្នុងវិស័យអប់រំ ។ សិក្ខាសាលារយៈពេលមួយថ្ងៃនេះធ្វើឡើងនៅសណ្ឋាគារសាន់វេក្នុងទីក្រុង ភ្នំពេញ មានការអញ្ជើញចូលរួមដោយបុគ្គលិកមកពីអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិជាង ៥៩ អង្គការ បានដំណើរការនិងបញ្ចប់ដោយទទួលបានជោគជ័យយ៉ាងធំធេង ។ NEP បានបញ្ជាក់ថាសិក្ខាកាមចូលរួមជាក់ស្តែងមានចំនួនជាង ១០០នាក់ដែលជាចំនួនលើសការរំពឹងទុកថាអាចមានសិក្ខាកាមត្រឹមតែ ៨០នាក់ប៉ុណ្ណោះចូលរួម ។ សិក្ខាសាលាថ្នាក់ជាតិនេះទទួលបានការឧបត្ថម្ភពី USAID តាមរយៈអង្គការខេបដែលមានកិច្ចសន្យាប្រចាំឆ្នាំជាមួយ NEP ដើម្បីជួយក្នុងការរៀបចំសិក្ខាសាលានេះឡើងរៀងរាល់ឆ្នាំ និងជួយរៀបចំធ្វើលិខិតអញ្ជើញដល់បណ្តាញអង្គការសមាជិកដទៃទៀត ។

សិក្ខាសាលានេះត្រូវបានធ្វើបទបង្ហាញដោយបុគ្គលិកអង្គការអប់រំពិភពលោក និងអង្គការខេប អំពីបទពិសោធន៍ដែលទទួលបានពីឆ្នាំកន្លងមកមានដូចជា៖

- កម្មវិធីបំណិនជីវិត
- ការបង្កើតបន្ទប់កុំព្យូទ័រស៊ិនក្លាយអ៊ិន និងការបញ្ចូលICTក្នុងការបង្រៀន និងរៀន
- ការបង្កើតបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ
- យុទ្ធសាស្ត្រកាត់បន្ថយសិស្សបោះបង់ការសិក្សា
- ការបំប៉នអំពីការគ្រប់គ្រងសាលារៀន
- យុទ្ធសាស្ត្រដើម្បីដោះស្រាយកង្វះខាតគ្រូ

សិក្ខាសាលានេះទទួលបានការចាប់អារម្មណ៍យ៉ាងច្រើនពីអ្នកចូលរួមដោយមានការចោទសំនួរ និងចែករំលែកព័ត៌មានផងដែរ ។ ក្នុងអំឡុងពេលសិក្ខាសាលា IBEC ក៏បានអញ្ជើញសិស្សពីរនាក់មកពីវិទ្យាល័យប៊ុសពី ស្រុកក្រូចឆ្មារដើម្បីធ្វើបទបង្ហាញអំពីការបង្កើតព្រឹត្តិបត្រសាលារៀនដោយប្រើប្រាស់កុំព្យូទ័រ ។ ភាពជឿជាក់ និងបទពិសោធន៍របស់សិស្សទាំងពីរនេះជាភស្តុតាងដ៏ល្អមួយដែលបង្ហាញអំពីលទ្ធផលរបស់គម្រោងទៅលើយុវជន ។

### បណ្តាអង្គការក្រៅរដ្ឋាភិបាលនានាចុះទស្សនកិច្ចសាលារៀនរបស់ IBEC

តាមរយៈសិក្ខាសាលានេះដែរ NEP បានរៀបចំកម្មវិធីទស្សនកិច្ចសិក្សារយៈពេល២ថ្ងៃទៅកាន់សាលារៀនរបស់គម្រោង IBEC នៅក្នុងខេត្តសៀមរាបដើម្បីមើលសកម្មភាពដែលអនុវត្តល្អមួយចំនួន ។ នៅថ្ងៃទី ២២ ខែ មិថុនា បុគ្គលិកមកពីអង្គការក្រៅរដ្ឋាភិបាលចំនួន៤០បានធ្វើទស្សនកិច្ចសិក្សាទៅកាន់សាលារៀនចំនួន២គឺអនុវិទ្យាល័យ សាមគ្គី និងបឋមសិក្សាហ៊ុនសែនគំរូស្លិតក្នុងស្រុកជីក្រែង ។ ដំណើរទស្សនកិច្ចនេះធ្វើឡើងដើម្បីបញ្ជាក់បន្ថែមអំពីសិក្ខាសាលាដោយផ្តល់នូវឧទាហរណ៍ជាក់ស្តែងអំពីសកម្មភាពមួយចំនួនដែលបានពិភាក្សាអំឡុងពេលសិក្ខាសាលា ។ ភ្ញៀវបានមើលសកម្មភាពមួយចំនួនដូចជា ការប្រើប្រាស់បន្ទប់កុំព្យូទ័រ ការប្រើប្រាស់បន្ទប់ពិសោធន៍ សកម្មភាពបំណិនជីវិតមាន ការចិញ្ចឹមត្រី ដំណាំបន្លែ និងសកម្មភាពក្រុមប្រឹក្សាកុមារក៏ដូចជាបន្ទប់មុខវិជ្ជាជាដើម ។ ទស្សនកិច្ចនេះទទួលបានលទ្ធផលជោគជ័យដោយសារមានចំណាប់អារម្មណ៍លើការយកទៅអនុវត្តបន្តនៅតាមខេត្ត និងគម្រោងផ្សេងៗទៀត ៕



ការលើកកម្ពស់ការយល់ដឹងផលប៉ះពាល់របស់គម្រោង ៖ អង្គការ NEP មើលការពិសោធន៍ក្នុងសាលារៀន

ព្រឹត្តិបត្រព័ត៌មាននេះអាចផលិតទៅបានដោយមានការឧបត្ថម្ភ ក្រោមជំនួយសប្បុរសធម៌ពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។
រាល់ខ្លឹមសារនៅក្នុងព្រឹត្តិបត្រនេះ ជាការទទួលខុសត្រូវរបស់អង្គការអប់រំពិភពលោក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID ឬរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។
ការិយាល័យអង្គការអប់រំពិភពលោក ៖ ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ ៨៥៥-២៣-២១៦ ៨៥៤ ទូរសារលេខ ២១៨ ៣៦៩ E-mail: worldedcam@worlded.org.kh

# សមាសភាគ១ ៖ ការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងការស្វែងរកការគាំទ្រដើម្បីនិរន្តរភាព

ក្រុមការងារក្នុងសមាសភាគនេះបានធ្វើការពិនិត្យឡើងវិញអំពីដំណើរការចូលរួមរបស់អង្គការដៃគូក្នុងស្រុកក្នុងការបញ្ចប់ផែនការស្តង់ដាដែលបានធ្វើសេចក្តីព្រាងកាលពីដើមឆ្នាំកន្លងទៅ ។ ជាមធ្យមអង្គការដៃគូទាំងអស់សម្រេចបានប្រហែល៦២% នៃផែនការស្តង់ដាដែលបានកំណត់ ៣០% កំពុងដំណើរការ និង៨% ត្រូវបានពន្យាពេលដោយសារមូលហេតុផ្សេងៗ ។ ការពិនិត្យឡើងវិញទៅលើឯកសារហិរញ្ញវត្ថុក៏បានធ្វើឡើងចំពោះគ្រប់អង្គការដៃគូទាំងអស់ផងដែរ ក្នុងគោលបំណងបញ្ជាក់ពីគណនេយ្យភាព និងឲ្យស្របទៅតាមការណែនាំរបស់ USAID ។

IBEC ក៏បានជួយដល់សាលាធនធានមួយចំនួនក្នុងការរៀបចំផែនការអំពីរបៀបប្រើប្រាស់កញ្ចប់ថវិកាពិសេសសម្រាប់អភិវឌ្ឍន៍បណ្ណាល័យ រៀបចំកម្មវិធីរកប្រាក់ចំណូលដែលផ្សារភ្ជាប់នឹងកម្មវិធីបំណិនជីវិត និងសកម្មភាពដទៃមួយចំនួនទៀត ។ សាលាក៏បានពិនិត្យឡើងវិញផងដែរនូវផែនការនិរន្តរភាពដែលជួយជ្រោមជ្រែងដោយបុគ្គលិក IBEC ។ សមាសភាគ១ និងសមាសភាគ៣បានទទួលជោគជ័យយ៉ាងពេញលេញក្នុងការសហការរបស់ពួកគេលើសកម្មភាពដែលទាក់ទងទៅនឹងនិរន្តរភាព និងការអភិវឌ្ឍទូទៅក្នុងសាលារៀន ។

នេះជាលើកទីមួយដែលមន្ត្រីក្រុមការងារថ្នាក់ខេត្តបានចូលរួមជាមួយបុគ្គលិក IBEC ក្នុងការចុះត្រួតពិនិត្យសកម្មភាពរបស់សាលារៀននៅពាក់កណ្តាលឆ្នាំ ដើម្បីធ្វើការតាមដានពិនិត្យឡើងវិញ និងធ្វើការដោះស្រាយបញ្ហាឲ្យទាន់ពេលវេលា ។

ការចុះត្រួតពិនិត្យនេះគឺដើម្បីធ្វើការវាយតម្លៃលើការអនុវត្តចំពោះអន្តរាគមន៍ទាំងឡាយនិងការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុដែលគម្រោងបានផ្តល់ឲ្យ ។

IBEC បានពង្រឹងសកម្មភាពកសាងសមត្ថភាពគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ (CEFAC) របស់ខ្លួនក្នុងគោលបំណងប្តូរឥរិយាបទក្រុមប្រឹក្សាឃុំក្នុងការផ្តល់ថវិកាបដិភាគសម្រាប់សាលារៀនដើម្បីអនុវត្តកម្មវិធីរបស់គម្រោងក្នុងឆ្នាំ ២០១៣ ។ ឯកសារណែនាំដែលជួយដល់ឃុំគោលដៅទាំងអស់ត្រូវបានបោះពុម្ពក្នុងត្រីមាសនេះ ៕



ការបង្កការចូលរួមពីសហគមន៍ ៖ សមាជិកCEFAC រៀនអំពីការអភិវឌ្ឍ

## រឿងជោគជ័យ ៖ ការប្រលងអំពីការបង្កើតខ្សែអាត់វិទ្យុបណ្តុះគំនិតដល់យុវជន

តាមរយៈការទទួលបានជោគជ័យ និងការចូលរួមរបស់សិស្សយ៉ាងសកម្មនៅក្នុងការប្រលងអំពីការបង្កើតខ្សែអាត់វិទ្យុកាលពីលើកទី១ អង្គការ Equal Access (EA) បានរៀបចំការប្រលងលើកទី២ ដើម្បីជម្រុញឲ្យសិស្សអនុវត្ត និងពង្រីកបំណិនថ្មីៗថែមទៀតបន្ទាប់ពីការបំប៉នរបស់អង្គការ EA ។ ការប្រឡងនេះតម្រូវឲ្យសិស្ស និងគ្រូដឹកនាំធ្វើការរួមគ្នាជាក្រុមដើម្បីរៀនពីរបៀបបែងចែកតួនាទី និងការទទួលខុសត្រូវរវាងសមាជិកក្រុម ។ ការចូលរួមរបស់សិស្សរីកចម្រើនហួសពីការរំពឹងទុករបស់បុគ្គលិកអង្គការ EA និងគ្រូដឹកនាំដែលបាគិតថាសិស្សតូចៗនឹងមិនអាចបង្កើតខ្សែអាត់វិទ្យុដែលមានខ្លឹមសារកម្រិតខ្ពស់ និងសំលេងបានល្អនោះទេព្រោះការបំប៉នអំពីជំនាញយកព័ត៌មានមានរយៈពេលខ្លី ។ អ្នកគ្រូ ស៊ុន សុភាព ជាគ្រូដឹកនាំបានសម្តែងចំណាប់អារម្មណ៍ថាការប្រលងបែបនេះមានប្រយោជន៍ណាស់ពីព្រោះ វាមិនត្រឹមតែឲ្យសិស្សមានមោទនភាពប៉ុណ្ណោះទេ វាថែមទាំងបានបង្កើតនូវចំណេះដឹង និងជំនាញផ្ទាល់ខ្លួនអំពីការសម្របសម្រួល ការចរចារ និងការប្រាស្រ័យទាក់ទងគ្នា ។ អ្នកគ្រូ ពេជ្រ វណ្ណា ដែលជាគ្រូដឹកនាំម្នាក់ទៀតបានបន្ថែមថាការបង្រៀនឲ្យសិស្សធ្វើជាអ្នកយកព័ត៌មានមានសារៈសំខាន់ណាស់ពីព្រោះ វាជួយផ្តល់នូវទស្សនវិស័យផ្សេងៗគ្នាបន្ថែមទៅលើការសិក្សាក្នុងសាលារៀន និងការសប្បាយរីករាយនៅពេលសម្ភាសគ្រូបង្រៀន សិស្សរួមសាលា និងមនុស្សក្នុងសហគមន៍ផ្សេងៗទៀត ។ កុមារី ហាម ស្រីមិច អាយុ១៥ឆ្នាំនៅវិទ្យាល័យហ៊ុនសែន ប៉ើសពីដែលបានទទួលជ័យជំនះបាននិយាយថា “ខ្ញុំចូលចិត្តសម្ភាសខ្លាំងណាស់ពីព្រោះវាជួយបង្កើនចំណេះដឹង និងទំនុកចិត្តរបស់ខ្ញុំ ។ ខ្ញុំមានមោទនភាពណាស់ដែលបានធ្វើជាអ្នកយកព័ត៌មាន” ៕

## ការអប់រំផ្សព្វផ្សាយតាមរយៈវិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀត



ក្រុមសិស្សចុះយកព័ត៌មានធ្វើសម្ភាសមិត្តរួមថ្នាក់ក្នុងសហគមន៍របស់ពួកគេ

ដៃគូគម្រោង IBEC អង្គការ Equal Access (EA) បានបញ្ចប់ផែនការធំមួយស្តីអំពីសកម្មភាពផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗក្នុងត្រីមាសនេះ ។ សិស្សបានចូលរួមស្តាប់កម្មវិធីវិទ្យុចំនួនពី៩ទៅ១០កម្មវិធីក្នុងឆ្នាំនេះ និងចូលរួមកម្មវិធីសំនួរចំលើយតាមរយៈកម្មវិធីវិទ្យុដែលបានផ្សាយលើកទី៩ និងទី១០ អានសៀវភៅតុក្កតាទី៣ និងទី៤ និងសកម្មភាពនៅក្នុងសាលារៀនជាច្រើនទៀតដូចជា ក្រុមស្តាប់ពិភាក្សា និងក្រុមរាយការណ៍ព័ត៌មាន ។ តាមរបាយការណ៍ពី EA ថាមានសិស្សជាង ៤០០០នាក់ បានចូលរួមប្រជុំតាមសាលារៀន និងការបង្ហាញពីប្រជាប្រិយភាពរបស់កម្មវិធីតាមរយៈការស្រាវជ្រាវពីក្រុមអ្នកស្តាប់ ។ មកទល់ពេលនេះការផ្តល់ឱកាសឲ្យយុវជនកម្ពុជាបង្ហាញពីយោបល់ខ្លួនឯងផ្ទាល់តាមរយៈប្រព័ន្ធផ្សព្វផ្សាយគឺជាការផ្តល់ប្រយោជន៍យ៉ាងជាក់ច្បាស់មួយ ។ តាមរយៈនៃការបង្ហាញចុងក្រោយនេះជាលទ្ធផល EA បានបង្កើតនូវភាពល្បីល្បាញតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលទាក់ទងនិងកម្មវិធីបំណិនជីវិតដែលជាមធ្យោបាយបង្កើននូវនិរន្តរភាពគម្រោង ៕

## សមាសភាគ២ ៖ ការបង្កលទ្ធភាពទទួលបានការអប់រំប្រកបដោយសមធម៌

### កញ្ចប់អំណោយសាលារៀនដែលដឹកនាំដោយអ្នកពាក់ព័ន្ធ

ក្នុងអំឡុងពេលត្រីមាសនេះ ក៏ជាពេលដែលវិស្សមកាលថ្មីជិតចូលមកដល់ IBEC បានបង្កើនការចូលរួមរបស់ខ្លួនក្នុងការបំប៉នសាលារៀនលើការថែរក្សា និងប្រើប្រាស់សម្ភារៈដែលផ្តល់ជូនឲ្យបានត្រឹមត្រូវ និងមានភាពងាយស្រួល ។ ក្រោយពេលដែលបានបញ្ចប់វគ្គសិក្ខាសាលាបំប៉ននេះ លោកគ្រូ អ្នកគ្រូបានអនុវត្តសកម្មភាពទាំងនោះបន្តជាមួយសិស្សរបស់ពួកគាត់បានចំនួន ៣៨,៥៤២នាក់ ។ សកម្មភាពដែលសម្រេចបានជាក់ស្តែងក្នុងត្រីមាសនេះមាន ៖

- ហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធទឹកស្អាតដែលនៅសល់ត្រូវបានបញ្ចប់នៅដើមត្រីមាសនេះស្ទើរតែទាំងស្រុង ។
- ក្រុមការងារបានបញ្ចប់នូវការស្វែងរកអត្រាសិស្សប្រើប្រាស់បណ្ណាល័យពីគ្រប់សាលា យើងបានរកឃើញថាមានអត្រាប្រើប្រាស់កើនឡើងជាមធ្យមចំនួន ២០,៩៧នាក់ក្នុងមួយឆ្នាំសិក្សាកន្លងទៅ ជាការរកឃើញដែលផ្តល់នូវការលើកទឹកចិត្តក្នុងការវិនិយោគលើកម្មវិធីលើកកម្ពស់ការអាន។
- IBEC បានសម្របសម្រួលការព្យាបាលពិការភាពរូបរាងកាយរបស់កុមារចំនួន៥២នាក់ (ស្រី ១៧នាក់) ភាគច្រើនពួកគេមកពីខេត្តកំពង់ចាម និងសៀមរាប ការព្យាបាលពិការភាពនេះគឺដើម្បីជួយកុមារក្នុងការបន្តការសិក្សារបស់ពួកគេ ។
- បណ្តាញទីប្រឹក្សាកុមារីដែលបានបង្កើតកាលពីដើមឆ្នាំបានរាយការណ៍ថាបណ្តាញគាំទ្រកើនឡើងចំនួន ២,៧៤១ ។ បណ្តាញនេះផ្តោតជាសំខាន់ទៅលើកុមារីមកពីអនុវិទ្យាល័យ និងវិទ្យាល័យឲ្យអ្នកសទាញមិត្តភ័ក្តិរបស់ពួកគេដើម្បីបន្តការសិក្សា និងតាមដានរយៈពេលអវត្តមានរបស់គេដោយក្រុមកុមារស្ម័គ្រចិត្ត ។

### រឿងជោគជ័យ ៖ អ្នកគ្រូម្នាក់បានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងធំ



អ្នកគ្រូសុខុមនិយាយជាមួយលោកនាយកអំពីវិធីសាស្ត្រជួយកុមារី



ស្រីម៉ិចរៀនថ្នាក់ទី៨បានត្រឡប់មកសិក្សាវិញបន្ទាប់ពីមានការណែនាំពីអ្នកគ្រូសុខុម

អ្នកគ្រូ ពេជ្រ សុខុម ជាគ្រូឆ្នើមមួយរូបគាត់មានអាយុ២២ឆ្នាំបង្រៀននៅអនុវិទ្យាល័យជ័យយោក្នុងខេត្តកំពង់ចាម ។ គាត់បានធ្វើការយ៉ាងច្រើនជាមួយកុមារីដែលបោះបង់ចោលសាលា គាត់ជាញឹកញាប់តែងតែចុះទៅដល់ផ្ទះរបស់ពួកគេដើម្បីណែនាំ និងផ្តល់ប្រឹក្សាទៅតាមអ្វីដែលគាត់បានសិក្សាពីគម្រោង IBEC ។ ចំនួនកុមារីបោះបង់ចោលការសិក្សាជាច្រើនបានត្រឡប់មកសិក្សាវិញដូចជាកុមារីឈ្មោះស្រីម៉ិចដែលបានទៅធ្វើការនៅទីក្រុងភ្នំពេញ ។ អ្នកគ្រូសុខុមបានជួបជាមួយគ្រួសាររបស់នាងហើយបាននិយាយជាមួយនាងតាមទូរស័ព្ទបន្ទាប់មកនាងបានសម្រេចចិត្តត្រឡប់មកបន្តការសិក្សាវិញ ៕

### អាហារូបករណ៍

IBEC បានបន្តត្រួតពិនិត្យដំណើរការផ្តល់អាហារូបករណ៍ទៅលើអ្នកទទួលផលទាំងអស់នៅបឋមសិក្សា និងមធ្យមសិក្សាក៏ដូចជានៅសាលាគរុកោសល្យក្នុងខេត្តទាំងបី ។ ស្ថិតិបានបង្ហាញថាមានសិស្សដែលទទួលអាហារូបករណ៍ប្រហែល៧% នៅមធ្យមសិក្សាបានបោះបង់ចោលការសិក្សាដែលមានអត្រាប្រហាក់ប្រហែលគ្នារវាងសិស្សប្រុស និងសិស្សស្រី ។ IBEC បានបញ្ចប់ការតាមដានចំពោះការបោះបង់នេះដោយបង្ហាញថា កាជួយកិច្ចការផ្ទះជាមូលហេតុចម្បងចំពោះការបោះបង់ការសិក្សា ។ គរុសិស្សដែលទទួលអាហារូបករណ៍ទាំង៧២នាក់បានប្រលងជាប់ដោយជោគជ័យ គម្រោងនឹងធ្វើការពិភាក្សាជាមួយមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម និងក្រចេះអំពីការបែងចែកគរុសិស្សទាំងនេះទៅសាលារៀនគោលដៅរបស់គម្រោងដែលកំពុងខ្វះខាតគ្រូ ។

កិច្ចប្រជុំថ្មីៗជាមួយក្រុមការងារអនុវិស័យផ្នែកបណ្តុះបណ្តាលគ្រូ នៃក្រសួងអប់រំ យុវជន និងកីឡាបានកោតសរសើរដល់គម្រោងក្នុងកិច្ចប្រឹងប្រែងរបស់ខ្លួនក្នុងការធ្វើការជាមួយនាយកដ្ឋានបណ្តុះបណ្តាលគ្រូ និងមន្ទីរអប់រំខេត្តដើម្បីផ្តល់អាហារូបករណ៍គរុសិស្សដែលជាបេក្ខជនមកពីតំបន់ដាច់ស្រយាល ។ USAID បានផ្តល់អាហារូបករណ៍ដល់គរុសិស្សចំនួន២៤១នាក់ចាប់តាំងពីឆ្នាំ២០០៤ ជាមួយនឹងផែនការរើសបន្ថែមថ្មីចំនួន១២០នាក់ទៀតនៅឆ្នាំក្រោយ ។ ក្រសួងអប់រំស្នើសុំដល់ម្ចាស់ជំនួយដទៃទៀតឲ្យជួយគាំទ្រដល់ការវិនិយោគបែបនេះក្នុងខេត្តដទៃទៀតដែរ ៕

### ករណីសិក្សា ៖ សកម្មភាពអភិវឌ្ឍល្អនឹងធានាបាននូវការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព



*ចាន់ធ្វើបទបង្ហាញរបស់នាងនៅក្នុងថ្នាក់*

យៀន ចាន់ មានអាយុ១៨ឆ្នាំ ជាគរុសិស្សឆ្នាំទី២នៅសាលាគរុកោសល្យ និងវិក្រឹត្តការខេត្តកំពង់ចាម ។ នាងបានទទួលអាហារូបករណ៍ពីអង្គការខេប ចាប់តាំងពីនាងរៀន ថ្នាក់ទី៧មកម្លេះ នៅពេលដែលនាងបានបញ្ចប់ថ្នាក់ទី៩ នាងក៏មានឱកាសទទួលបានអាហារូបករណ៍ដើម្បីបន្តការសិក្សានៅសាលាគរុកោសល្យ ដែលគាំទ្រដោយ USAID ក្នុងការអភិវឌ្ឍធនធានមនុស្ស នាងនឹងត្រូវត្រឡប់ទៅបង្រៀននៅសហគមន៍របស់នាងវិញនៅពេលដែលបញ្ចប់ការសិក្សាក្នុងឆ្នាំនេះ ។ ចាន់និយាយថា នាងមានសំណាងណាស់ដែលទទួលបានឱកាសដ៏ល្អនេះ នាងគឺជាកូនម្នាក់ក្នុងចំណោមកូន៥នាក់ក្នុងគ្រួសាររបស់នាង បងប្អូននាងភាគច្រើនបានបោះបង់ចោលការសិក្សាតាំងពីថ្នាក់ទី៦មកម្លេះដោយសារតែភាពក្រីក្រ ប៉ុន្តែដោយសារអាហារូបករណ៍របស់អង្គការខេបដែលផ្តល់ឲ្យនាងកាលពីថ្នាក់ទី៧ បានផ្តល់លទ្ធភាពឲ្យនាង និងប្អូនស្រីរបស់នាងអាចបន្តការសិក្សា ។ ដោយសារតែក្រសួងអប់រំ យុវជន និងកីឡាមានការកែប្រែថ្មីដោយអនុញ្ញាតឲ្យសិស្សដែលរៀនចប់ថ្នាក់ទី៩អាចប្រលងចូលរៀននៅសាលាគរុកោសល្យបានបូករួមនឹងអាហារូបករណ៍របស់ USAID ផងនោះ នាងក៏ទទួលបានឱកាសពិសេសដើម្បីក្លាយទៅជាគ្រូម្នាក់ដែលជាសុបិនក្នុងជីវិតរបស់នាង ។

ចាន់ ប្រឹងប្រែងសិក្សាយ៉ាងខ្លាំងហើយបានជាប់ការប្រលងបញ្ចប់ការសិក្សារបស់នាងក្នុងឆ្នាំនេះ នាងនិយាយថា នាងសប្បាយរីករាយយ៉ាងខ្លាំងដោយបានត្រឡប់ទៅបង្រៀននៅក្នុង សហគមន៍របស់នាងក្នុងស្រុកត្បូងឃ្មុំ ។ នាងបន្តថា នាងនឹងព្យាយាមប្រឹងប្រែងដើម្បីក្លាយជាគ្រូល្អម្នាក់ និងធ្វើជាគំរូដល់សិស្សដទៃដើម្បីឲ្យពួកគេស្គាល់ពីតម្លៃនៃការអប់រំ ។ នាងមានភាពអស្ចារ្យយ៉ាងខ្លាំងដែលទទួលបានឱកាសក្លាយជាគ្រូបង្រៀនបើទោះជានាងមកពីគ្រួសារក្រីក្រក្នុងសហគមន៍ដាច់ស្រយាលក៏ដោយ ៕

## សមាសភាគ៣ ៖ ការកែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍

IBEC បានជួយគ្រូបង្គោលដែលបានជ្រើសរើសចេញពីបុគ្គលិកក្រសួងអប់រំ យុវជន និងកីឡាក្នុង មូលដ្ឋានដើម្បីឲ្យពួកគាត់បន្តធ្វើការតាមដានសកម្មភាពក្នុងសាលារៀន និងថាតើកិច្ចការរដ្ឋបាលដែលបានដាក់ឲ្យក្នុងពេលធ្វើសិក្ខាសាលាកាលពីខែមករាដំណើរការបានល្អយ៉ាងណា ។ វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន (SMLTC) ដែលបានបង្កើត និងអនុវត្តជាង២ឆ្នាំមកហើយនោះបានឈានដល់ការផ្តល់វិញ្ញាបនប័ត្រដល់នាយកសាលា និងបុគ្គលិករដ្ឋបាលនៅតាមសាលាគោលដៅ ។ គ្រូបង្គោលចំនួន១៧នាក់បានចុះតាមដានកិច្ចការរដ្ឋបាលរបស់បុគ្គលិកសាលារៀនចំនួន៩៤១នាក់ដើម្បីប្រមូលព័ត៌មានដែលនឹងត្រូវប្រើក្នុងការសម្រេចចិត្តផ្តល់វិញ្ញាបនប័ត្រ ។

ទាក់ទងនឹងដំណើរការដែលអនុវត្តដោយគណៈកម្មការទ្រទ្រង់សាលាទៅលើចំនួនសាលាដែលបានចូលរួមបានបង្ហាញពីលទ្ធផលគួរឲ្យកត់សម្គាល់ពីការចូលរួមរបស់សាលាច្រើនជាងឆ្នាំមុន ។ ក្រុមការងារក៏បានធ្វើការចុះតាមដានដោយចៃដន្យទៅលើគ្រួសារដែលជួបការលំបាក (គ្រួសារដែលទទួលអាហារូបករណ៍) ដើម្បីពិនិត្យមើលពីប្រសិទ្ធភាពនៃសកម្មភាពរបស់គម្រោង និងស្វែងរកផលប៉ះពាល់អំពីការបោះបង់ដោយសង្កត់ធ្ងន់លើករណីមួយចំនួន ។ គ្រួសារមួយចំនួននោះបានរាយការណ៍ថាពួកគេទទួលបានប្រាក់ចំនូលខណៈពេលដែលកូនៗរបស់ពួកគេមានលទ្ធភាពក្នុងការអនុវត្តសកម្មភាពបំណិនជីវិតដែលគេបានរៀន ជារួមគម្រោងបានជួយឧបត្ថម្ភគ្រួសារជួបការលំបាកចំនួន៣២៩គ្រួសារដែលកូនៗរបស់ពួកគេទទួលបានអាហារូបករណ៍ពីគម្រោង IBEC ៕

## សមាសភាគ៤ ៖ ការកែលម្អបរិបទទំនាក់ទំនងអប់រំ

### ការគាំទ្រផ្នែកបច្ចេកវិទ្យាព័ត៌មាន

ព្រឹត្តិការណ៍ធំបំផុតក្នុងត្រីមាសនេះគឺការធ្វើពិពណ៌ការងារគម្រោង ក្នុងឆ្នាំនេះមានពិពណ៌ចំនួន៣ដែលធ្វើឡើងក្នុងខេត្តនីមួយៗ ។ នេះគឺជាព្រឹត្តិការណ៍ដ៏ពិសេសមួយដែលក្រុមសិស្សត្រូវធ្វើបទបង្ហាញតាមរយៈកម្មវិធី PowerPoint អំពីប្រធានបទដែលពួកគេបានស្រាវជ្រាវដោយប្រើប្រាស់បន្ទប់កុំព្យូទ័រ ។ IBEC ទទួលបានជោគជ័យក្នុងការប្រើវិធីសាស្ត្រការងារគម្រោងដែលជាផ្នែកមួយនៃយុទ្ធសាស្ត្រគន្លឹះក្នុងការធ្វើសមាហរណកម្មជំនាញព័ត៌មានវិទ្យាក្នុងការបង្រៀន និងរៀន ។ ដោយឡែកមានសិស្សមួយក្រុមផ្សេងទៀតបានធ្វើបទបង្ហាញរបស់ខ្លួនស្តីអំពីការបង្កើតព្រឹត្តិប័ត្រសាលារៀននៅក្នុងសិក្ខាសាលាដែលរៀបចំដោយ NEP ។

IBEC បានបញ្ចប់ការចុះតាមដានវាយតម្លៃរបស់ខ្លួនទៅលើរបៀបគ្រប់គ្រង និងការប្រើប្រាស់បន្ទប់កុំព្យូទ័រមានឥទ្ធិពលទៅលើការសិក្សារបស់សិស្សកម្រិតណា ។ សិស្សចំនួន ៣០% បានរាយការណ៍ថាយ៉ាងហោចណាក់ពួកគេបានរៀនកុំព្យូទ័ររយៈពេលមួយម៉ោងក្នុងមួយសប្តាហ៍ ខណៈពេលដែលមានសិស្សចំនួន ៦៩% ទៀតបានរៀន២ម៉ោង ឬច្រើនជាងនេះក្នុងមួយសប្តាហ៍ ក្នុងនោះផងដែរសិស្សចំនួន ៧២% បង្ហាញថា វត្តមានរបស់បន្ទប់កុំព្យូទ័រនៅក្នុងសាលារៀនរបស់ពួកគេ ជាមូលហេតុចម្បងឲ្យពួកគេសម្រេចចិត្តបន្តការសិក្សា ។ នេះជាការរកឃើញថាការអនុវត្តកម្មវិធីកុំព្យូទ័រនៅតាមសាលារៀននៅតែបន្តជះឥទ្ធិពលវិជ្ជមានយ៉ាងខ្លាំង ៕

### ព្រឹត្តិការណ៍សំខាន់ ៖ សៀវភៅមេរៀនបំណិនជីវិតស្ទើរតែបញ្ចប់ទាំងស្រុង




ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូថ្នាក់ក្រសួងសមាសភាគទី៤បានបញ្ចប់នូវការបោះពុម្ពសៀវភៅមេរៀនបំណិនជីវិតចំនួន២៨ប្រភេទក្នុងចំណោម៣០ គឺជាផ្នែកមួយនៃកម្មវិធីសិក្សាបំណិនជីវិតដែលនឹងត្រូវដាក់ឲ្យដំណើរការសាកល្បងនៅឆ្នាំក្រោយ ។ នេះគឺជាស្នាដៃដ៏សំខាន់មួយរបស់គម្រោង IBEC នៅក្នុងត្រីមាសនេះ ក្រុមការងារបានរៀបចំសិក្ខាសាលាជាច្រើនជាមួយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងនាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈដើម្បីកែសម្រួលសៀវភៅមេរៀននេះឲ្យមានលក្ខណៈស្តង់ដា ។ ជាងនេះទៅទៀតក្រសួងអប់រំបានយល់ព្រមឲ្យបោះពុម្ពសៀវភៅសិក្សាទាំងនេះដោយដាក់និមិត្តសញ្ញារបស់ក្រសួងទៀតផង ។ នេះមិនត្រឹមតែបង្ហាញអំពីភាពជាម្ចាស់របស់សៀវភៅនេះទេ ប៉ុន្តែវាធ្វើឲ្យលោកគ្រូ អ្នកគ្រូ និងនាយកសាលាមានអារម្មណ៍ជឿជាក់ក្នុងការប្រើប្រាស់សៀវភៅនេះ ក្នុងខែកន្លងទៅថ្មីនេះ IBEC បានទទួលនូវសំណួរជាច្រើនពីអង្គការក្រៅរដ្ឋាភិបាលនានាដែលពួកគេចង់ដឹងអំពីកម្មវិធីបំណិនជីវិតដែលគម្រោងកំពុងអនុវត្ត សកម្មភាពនេះបង្ហាញអំពីការរីកចម្រើនក្នុងកម្រិតជាតិទាំងមូល ។ អ្វីៗទាំងអស់បានរៀបចំរួចជាស្រេចសម្រាប់ការសាកល្បងកម្មវិធីបំណិនជីវិតដែលនឹងត្រូវចាប់ផ្តើមនៅខែតុលាខាងមុខនេះ ៕




*ខិត្តប័ណ្ណស្តីពីការធ្វើកសិកម្មស្រូវ*

### ការបណ្តុះបណ្តាលគ្រូ



លទ្ធផលក្នុងថ្នាក់ ៖ គ្រូបានបោះបង់ចោលវិធីសាស្ត្របង្រៀនដោយការសរសេរលើក្តាខៀន និងនិយាយ

ការចុះវាយតម្លៃគ្រូដោយបុគ្គលិករបស់ IBEC ត្រូវបានបញ្ចប់ហើយលទ្ធផលបានបង្ហាញថា គ្រូភាគច្រើនមានលទ្ធភាពក្នុងការគ្រប់គ្រងថ្នាក់រៀន និងប្រើវិធីសាស្ត្រក្នុងការបង្រៀន និងរៀនបានយ៉ាងមានប្រសិទ្ធភាព ។ ការវាយតម្លៃជាទូទៅបានរកឃើញថាគ្រូកុមារមេត្រីកម្រិតមធ្យមចំនួន៩០% គ្រូកុមារមេត្រីថ្នាក់បឋមចំនួន៩៥% និងគ្រូសហគមន៍ចំនួន៧៤% ទទួលបានការវាយតម្លៃគួឲ្យពេញចិត្ត ។ ជាលទ្ធផលវិជ្ជមានគឺយើងមានគ្រូជំនួយពីរភាសាជួយសម្របសម្រួលក្នុងពេលបង្រៀន សិស្សចំនួន៨០៨នាក់ក្នុងចំណោមសិស្ស៩០៨នាក់ក្នុងថ្នាក់ដែលមានគ្រូជំនួយពីរភាសាត្រូវបានឡើងថ្នាក់ក្នុងពេលបញ្ចប់ត្រីមាសនេះ ៕